អង្គការរ៉ឺម៉កកម្ពុជា
សម្រាប់កុមារ R4C

ចាប់ផ្តើម


អាហារ



សត្វគ្រប់ប្រភេទ


មុខរបរ


អារម្មណ៍


សម្ភារសាលារៀន


អាហារ


សត្វគ្រប់ប្រភេទ


មុខរបរ


អារម្មណ៍


សម្ភារសាលារៀន



អាហារ



សត្វគ្រប់ប្រភេទ



មុខរបរ


អារម្មណ៍


សម្ភារសាលារៀន


អាហារ


សត្វគ្រប់ប្រភេទ


មុខរបរ


អារម្មណ៍


សម្ភារសាលារៀន


អាហារ

អ្នកឈ្នះ

ល្បែងទស្សន៍ទាយកាយវិការតាមប្រធានបទ





Rotary

កម្មវិធីសិក្សា ៖

ចិត្តចលភាព ៖ បំណិនចលករធំ(ការហ្វឹកហាត់បង្កើនកម្លាំង និងការសម្របសម្រួលនៃចលនាសាច់ដុំតូច និងសាច់ដុំធំ)

វិទ្យាសាស្ត្រ ៖ អាហាររូបត្ថម្ភ(ចំណេះដឹងមូលដ្ឋានអំពីអាហារ និងអាហាររូបត្ថម្ភ៖ ប្រាប់បានពីឈ្មោះបន្លែ ផ្លែឈើ និងអាហារបីក្រុម) ការរស់នៅប្រចាំថ្ងៃ(ការស្វែងយល់ដោយសង្កេតប្រាប់បានពីឈ្មោះសត្វចិញ្ចឹម សត្វព្រៃ សត្វស្លាប ឬលើសពីនេះទៀត) (លក្ខណៈមេឃ និងអាកាសធាតុ) ប្រតិបត្តិដោយសុវត្ថិភាព(ការយល់ដឹងពីការប្រតិបត្តិខ្លួនដើម្បីសុវត្ថិភាព) អនាម័យ(ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារ និងសង្គម)

សិក្សាសង្គម ៖ ការយល់ដឹងពីខ្លួនឯង(ស្គាល់ពីអារម្មណ៍មួយចំនួនប្រាប់បានពីអារម្មណ៍ និងមូលហេតុដែលធ្វើឱ្យខ្លួនឯងសប្បាយចិត្ត ត្រេកអរ ភ័យខ្លាចនៅពេលដែលជួបនៅព្រឹត្តិការណ៍ណាមួយ)

គោលបំណង៖

(ចិត្តចលភាព) ៖ ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។ ប្រាប់បានពីវិធីដើរ លូន រត់ លោត វារ ចុះ និងឡើង បោះ តោងឡើង គប់ រមៀល បង្វិលខ្លួន រុញ និងទាញ ទៅតាមគោលដៅ និងចម្ងាយដែលបានកំណត់)។

(វិទ្យាសាស្ត្រ) ៖ ចូលចិត្តញ៉ាំបន្លែ ផ្លែឈើ និងអាហារសំបូរជីវជាតិ សហការស្តាប់យោបល់ និងឯកភាព គំនិត ដើម្បីសម្រេចការងាជាក្រុម។ ប្រយ័ត្ន និងការពារខ្លួននៅពេលមានបាតុភូតធម្មជាតិ។ ចៀសវាងសកម្មភាពមួយចំនួនដែលនាំឱ្យមានគ្រោះថ្នាក់ ការលេងតាមចិញ្ចើមថ្នល់។ ទម្លាប់ល្អក្នុងការធ្វើអនាម័យខ្លួនឯងជាប្រចាំដោយការហូបស្អាត ផឹកស្អាត និងរស់នៅស្អាត។

(សិក្សាសង្គម) ៖ ទំនាក់ទំនងល្អទាំងកាយវិការ និងសម្តីប្រកបដោយក្តីស្រលាញ់ជាមួយមនុស្សនៅជុំវិញខ្លួន។

រយៈពេល ៖ ៣០ នាទី

កម្រិតសិក្សា ៖ មធ្យម និងខ្ពស់

ឧបករណ៍ ៖ គ្រាប់ឡុកឡាក់ និងក្រដាសក្តារល្បែង សម្ភារសម្រាប់ចំណាំ ឬវត្ថុសម្គាល់របស់កុមារ។

ការរៀបចំ ៖ ធ្វើជាគ្រាប់ឡុកឡាក់ដែលមានចំនួនលេខ ពី១ដល់៦ និងត្រៀមក្រដាសក្តារល្បែងជាទំហំ A3 ដែលមានស្រាប់នៅក្នុងគេហទំព័ររបស់R4C។

សេក្តីណែនាំ ៖

១. ល្បែងទស្សន៍ទាយកាយវិការតាមប្រធានបទមាន ៨ពណ៌ដូចជាពណ៌ក្រហម លឿង បៃតង ស្វាយ ខៀវ ទឹកក្រូច បៃតងខ្ចី និងពណ៌ផ្ទៃមេឃ។

២. ពណ៌ក្រហមរូបបាយមានន័យថា អាហារ ,ពណ៌លឿងរូបទន្សាយមានន័យថា សត្វគ្រប់ប្រភេទ ,ពណ៌បៃតងរូបពេទ្យមានន័យថា មុខរបរ ,ពណ៌ស្វាយរូបមុខមានន័យថា អារម្មណ៍ ,ពណ៌ខៀវរូបសាលារៀនមានន័យថា សម្ភារសិក្សា ពណ៌ទឹកក្រូចរូបព្រះអាទិត្យភ្លឺមានន័យថា អាកាសធាតុ ,ពណ៌បៃតងខ្ចីរូបកង់មានន័យថា មធ្យោបាយធ្វើដំណើរ ,ពណ៌ផ្ទៃមេឃរូបសំពះមានន័យថា សកម្មភាពប្រចាំថ្ងៃ។

៣. ល្បែងនេះលេងជាក្រុម ២ ឬ៣នាក់ក៏បានអាស្រ័យលើចំនួនសិស្សក្នុងថ្នាក់។

៤. ចែកក្រដាសក្តារល្បែង និងសម្ភារលេងសម្រាប់ក្រុមនីមួយៗ ។


៥. ជ្រើសក្មេងម្នាក់បោះគ្រាប់ឡុកឡាក់ចាប់ផ្តើមដើរមុនគេពីពាក្យចាប់ផ្តើម(គ្រាប់ឡុកឡាក់លេខ១-៦)។


៦. ប្រសិនដើរដល់រូបបាយក្មេងត្រូវធ្វើកាយវិការអំពីចំណីអាហារហើយក្មេងដទៃទៀតត្រូវទស្សន៍ទាយថាជាអាហារអ្វី? ធ្វើបែបណាក៏បានទាល់តែអ្នកផ្សេងទៀតទាយត្រូវទើបអាចដល់វេនអ្នកបន្ទាប់ទៀត។


៧. អ្នកបន្ទាប់ប្រសិនបើពួកគេដើរដល់ប្រអប់ដែលមានរូបទន្សាយ ពួកគេត្រូវធ្វើកាយវិការគ្រាប់តាមសត្វប្រភេទណាក៏បាន ហើយអ្នកផ្សេងទៀតធ្វើការទស្សន៍ទាយថាជាសត្វអ្វី?


មានរូបគ្រូពេទ្យ ក្មេងត្រូវធ្វើកាយវិការតាមមុខរបរណាមួយ និងឱ្យគេទស្សន៍ទាយរហូតដល់ត្រឹមត្រូវ ។ រូបអារម្មណ៍ត្រូវធ្វើកាយវិការទឹកមុខអារម្មណ៍ណាមួយ និងឱ្យគេទស្សន៍ទាយរហូតដល់ត្រូវ ។


រូបសាលារៀនត្រូវធ្វើកាយវិការអំពីសម្ភារសិក្សា និងឱ្យគេទស្សន៍ទាយរហូតទាល់តែត្រូវ ។ ធ្វើបែបហ្នឹងរហូត ក្មេងណាដែលដើរដល់កន្លែងអ្នកឈ្នះមុន គឺជាអ្នកឈ្នះទី១ហើយអ្នកបន្ទាប់ គឺជាបន្ទាប់ទី២ ទី៣។

























































๕
๖ ๓ ๑ ๔
๖



๕
๖ ๓ ๑ ๔
๖



๕
๖ ๓ ๑ ๔
๖



๕
๖ ๓ ๑ ๔
๖


๕
๖ ๓ ๑ ๔
๖


๕
๖ ๓ ๑ ๔
๖


๕
๖ ๓ ๑ ๔
๖


๕
๖ ๓ ๑ ๔
๖


๕
๖ ๓ ๑ ๔
๖